ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ៤០នាក់ និងមានករណីជាសះស្បើយចំនួន ០១នាក់
## នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖** គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ មានដូចតារាងខាងក្រោមនេះ ៖

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៤០៦ | ១១១ | ២៩៥ | អ្នកឆ្លងថ្មី៖ **០២នាក់** |
| | ១.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៩០ | ៦៩ | ២១ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | ១.៣. ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ | ១៣៧ | ៧១ | ៦៦ | អ្នកឆ្លងថ្មី៖ **៣៨នាក់** |
| | **សរុបអ្នកមានវីរុសកូវីដ-១៩** | **៦៣៣** | **២៥១** | **៣៨២** | អ្នកឆ្លងថ្មី៖ **៤០នាក់** |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣៨៨ | ១០០ | ២៨៨ | អ្នកជាសះស្បើយថ្មី៖**០១នាក់** |
| | ២.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៨៨ | ៦៨ | ២០ | អ្នកជាសះស្បើយថ្មី៖០នាក់ |
| | **សរុបអ្នកព្យាបាលជាសះស្បើយ** | **៤៧៦** | **១៦៨** | **៣០៨** | អ្នកជាសះស្បើយថ្មី៖**០១នាក់** |
| ៣. | **អ្នកកំពុងសម្រាកព្យាបាល ៖** | | | | |
| | ៣.១មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន | ៤៥ | ២៧ | ២២ | ក្រសួងនឹងធ្វើការជូនដំណឹងបន្តទៀតនៅពេលដែលទទួលបានរបាយការណ៍សម្រាកព្យាបាលបន្ថែម ចំនួន **១៥នាក់** ទៀត (បើបូកបញ្ចូលទៅក្នុងចំនួនសរុប គឺ **១៥៧នាក់** កំពុងសម្រាកព្យាបាល) |
| | ៣.២. មន្ទីរពេទ្យបង្អែក ខេត្តប៉ៃលិន | ០១ | ០១ | ០ | |
| | ៣.៣.មន្ទីរពេទ្យបង្អែក ខេត្តបន្ទាយមានជ័យ | ០១ | ០ | ០១ | |
| | ៣.៤. មន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបង | ០ | ០ | ០ | |
| | ៣.៥.មន្ទីរពេទ្យបង្អែក ខេត្តឧត្តរមានជ័យ | ០ | ០ | ០ | |
| | ៣.៦.មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | ៤៣ | ២០ | ២៣ | |
| | ៣.៧. មណ្ឌលសុខភាពចាក់អង្រែ | ៣៥ | ២០ | ១៥ | |
| | ៣.៨.សាលារក្សាសន្តិភាពពហុសាស្ត្រកំពង់ស្ពឺ | ០២ | ០ | ០២ | |
| | ៣.៩. មន្ទីរពេទ្យបង្អែក ខេត្តព្រះសីហនុ | ០២ | ០២ | ០ | |



ទីស្តីការក្រសួងសុខាភិបាល ផ្ទះលេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨[illegible] / ៨៨៤ ៩០៩

| | | | | | |
|---|---|---|---|---|---|
| | ៣.១០.មន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្តាល | ០៩ | ០៥ | ០៤ | |
| | **សរុបអ្នកកំពុងសម្រាកព្យាបាល** | **១៤២** | **៧៥** | **៦៧** | |

**សូមកត់សម្គាល់ថា៖ ក្រសួងសូមធ្វើការកែតម្រូវមានដូចខាងក្រោម៖**

-មានអ្នកជំងឺជាស្ត្រីចំនួន ០១នាក់ បានប្តូរពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មកសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ។

-អ្នកជំងឺចំនួន ០២នាក់ ដែលមិនអាចទាក់ទងបាន និងមិនព្រមមកសម្រាកព្យាបាលនោះត្រូវបានក្រុមគ្រូពេទ្យយកមកដាក់សម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រួចរាល់ហើយ។

## ២. ព័ត៌មានប្រចាំថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

### ក. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ សរុបចំនួន ៤០នាក់

### ក.១. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ០២នាក់ ដែលជាអ្នកដំណើរចូលមកកម្ពុជា (មិនមែនជាពលករធ្វើដំណើរមកពីប្រទេសថៃ)

- ស្ត្រីជនជាតិចិន អាយុ ៣៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។
- ស្ត្រីជនជាតិចិន អាយុ ២២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

**សូមកត់សម្គាល់ថា៖** ដោយមានគោលបំណងធ្វើដំណើរទៅប្រទេសចិនវិញដូច្នេះស្ត្រីទាំង ០២នាក់បានទៅធ្វើតេស្តដើម្បីសុំវិញ្ញាបនបត្របញ្ជាក់សុខភាពកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១។ លទ្ធផលធ្វើតេស្តវត្ថុសំណាករបស់ស្ត្រីទាំង០២រូបនេះ ផ្តល់ដោយវិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល គឺ វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្នអ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ។

### ក.២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖ ចំនួន ៣៨នាក់ ដែលជាអ្នកពាក់ព័ន្ធទៅព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ

- បុរសជនជាតិចិន អាយុ ៣៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ ០៧នាក់ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

- ស្ត្រីជនជាតិខ្មែរ អាយុ ៣៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។

- ស្ត្រីជនជាតិចិន អាយុ ២៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៤២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ ០៧នាក់ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន។

- បុរសជនជាតិចិន អាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៣០ឆ្នាំ មានអាសយដ្ឋានស្នាក់ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិនឈ្មោះ អាយុ ២៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៥១ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ស្រុកកោះធំ ខេត្តកណ្តាល។
- ស្ត្រីជនជាតិវៀតណាម អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ ស្រុកកោះធំ ខេត្តកណ្តាល។

**សម្គាល់៖** បច្ចុប្បន្នអ្នកជំងឺ ០៩នាក់ខាងលើ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល។

- បុរសជនជាតិចិន អាយុ ៣១ឆ្នាំ មានអាសយដ្ឋានស្នាក់ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន  អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិវៀតណាម អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៤៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ កោះពេជ្រ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៣២ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- បុរសជនជាតិចិន អាយុ ៤៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ៦៤ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។
- ស្ត្រីជនជាតិចិន អាយុ ២៦ឆ្នាំ មានអាសយដ្ឋានស្នាក់នៅ រាជធានីភ្នំពេញ។

**សម្គាល់៖** ដោយក្រសួងទទួលបានលទ្ធផលវិភាគវិជ្ជមានវីរុសកូវីដ-១៩ ពីមន្ទីរពិសោធន៍វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នាវេលាម៉ោង ០៣ទាបភ្លឺទៅហើយ ដូច្នេះក្រុមការងារកំពុងតែធ្វើការចាត់ចែងទំនាក់ទំនងរកអ្នកជំងឺ ដើម្បី

ដាក់ឲ្យសម្រាកព្យាបាលដោយគ្រោងធ្វើការបែងចែក ចំនួន ០៧នាក់ យកទៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន រីឯអ្នកជំងឺចំនួន ០៨នាក់ ទៀតគ្រោងយកទៅដាក់សម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកជ័យជំនះខេត្តកណ្ដាល។ នៅពេលដែលមានព័ត៌មានជាក់លាក់លើកករណីអ្នកជំងឺទាំង ១៥នាក់ ខាងលើនេះក្រសួងនឹងរាយការណ៍ជំរាបជូនជាបន្តបន្ទាប់ទៀត។

**ខ. មានករណីជាសះស្បើយ ៖ ចំនួន ០១នាក់ ដែលជាអ្នកដំណើរចូលមកកម្ពុជា (មិនមែនជាពលករធ្វើដំណើរមកពីប្រទេសថៃ)**

- បុរសជនជាតិខ្មែរ អាយុ ២៣ឆ្នាំ មានអាសយដ្ឋានស្នាក់នៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ជាអ្នកធ្វើដំណើរមកពីប្រទេសគុយវ៉ែត បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជានៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន រាជធានីភ្នំពេញ។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្ដេចតេជោ ថីតា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លង សហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៨២៨ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃពុធ ១៣កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ✓



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩